# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៣

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 17-Jun-2013, 13:51
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង សាធារណៈ/Public

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

## សំណើបន្ទាន់ស្នើសុំកោះហៅសាក្សីសំខាន់ៗទាក់ទិននឹងទួលពោធិ៍ជ្រៃ

---

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ

Victor KOPPE

ព្រុំ ផល្លា

សួន វិសាល

Joshua ROSENSWEIG

Forest ONEILL GREENBERG

**ចម្លងជូន:**

**សហចៅក្រម**

**សហព្រះរាជអាជ្ញា:**

ជា លាង

Andrew CAYLEY

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ

Elisabeth SIMONNEAU-FORT

សហមេធាវីការពារក្តី នួន ជា (ក្រុមមេធាវីការពារក្តី) សូមដាក់សំណើ (“សំណើ”) ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅឈ្មោះ [redacted] ឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង៖

1. សំណើនេះ ជាសំណើចុងក្រោយរបស់មេធាវីការពារក្តីស្នើសុំឱ្យមានការផ្តល់សក្ខីកម្មដោយផ្ទាល់ជាផ្នែកនៃការជំនុំជម្រះក្តីក្នុងសំណុំរឿង០០២/០១ (ក្នុងទម្រង់បច្ចុប្បន្ន)។ មេធាវីការពារក្តី ដាក់សំណើនេះនៅពេលនេះ ដោយហេតុថាសក្ខីកម្មរបស់សាក្សីឈ្មោះ អ៊ុង ឆាត់ និងលឹម សាត ដែលបានផ្តល់នៅចំពោះអង្គជំនុំជម្រះសាលាដំបូងក្នុងសប្តាហ៍នៃថ្ងៃទី ២៩ ខែ មេសាឆ្នាំ ២០១៣ បង្ហាញថាការដឹងឮផ្ទាល់ខ្លួនរបស់ពួកគាត់អំពីព្រឹត្តការណ៍ ដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃមានភាពខុសគ្នាច្រើនពីភស្តុតាងដែលពួកគាត់បានផ្តល់ក្នុងកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”)។ សក្ខីកម្មនោះ គាំទ្រយ៉ាងខ្លាំងចំពោះជំហររបស់មេធាវីការពារក្តីដែលថា នួន ជា មិនមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ឡើយ។ ពេលនេះ មេធាវីការពារក្តី មានមូលដ្ឋានច្បាស់លាស់ក្នុងការសង្ស័យចំពោះភាពអាចជឿជាក់បាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សីផ្សេងទៀតពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ និងមានហេតុផលគ្រប់គ្រាន់ក្នុងការជឿជាក់ថាការពិនិត្យឱ្យបានលម្អិតជាងនេះលើភស្តុតាង នឹងបង្ហាញភាពហួសពីវិមតិសង្ស័យថាអង្គជំនុំជម្រះ មិនអាចរកឃើញថា នួន ជា មានពិរុទ្ធភាពចំពោះបទឧក្រិដ្ឋនៅទីតាំងនោះឡើយ។ ភាពត្រឹមត្រូវ និងសិទ្ធិជាសារវ័ន្តក្នុងការការពារក្តី តម្រូវឱ្យមានការកោះហៅ និងដាក់ឱ្យសួរដេញដោលសាក្សីបន្ថែមដែល ក.ស.ច លើកយកមកសំអាង។

## I. ប្រវត្តិនីតិវិធី

2. កាលពីថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានរៀបចំធ្វើកិច្ចប្រជុំរៀបចំសវនាការដើម្បីស្តាប់សំណើរបស់ភាគីដែលត្រូវស្តាប់សក្ខីកម្មសាក្សីបន្ថែមក្នុងសំណុំរឿង០០២/០១។ មេធាវីការពារក្តី ស្នើឱ្យអង្គជំនុំជម្រះកោះហៅលោក [redacted] ជាសំខាន់ដោយសារគាត់នឹងផ្តល់សក្ខីកម្មថាមិនមានគោលនយោបាយបក្សកុំម្មុយនីស្តកម្ពុជាដូចត្រូវបានចោទប្រកាន់ថាបានសម្លាប់

អតីតមន្ត្រីសាធារណរដ្ឋខ្មែរទេ[1]។ កាលពីថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលសំណើនេះដោយមិនផ្តល់សំអាងហេតុឡើយ[2]។

3. កាលពីថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូង បានឆ្លើយតបទៅនឹងសំណើទីពីរ របស់សហព្រះរាជអាជ្ញាស្នើឱ្យពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១។ អង្គជំនុំជម្រះសាលា ដំបូង បានជំទាស់ចំណុចភាគច្រើនសំណើនោះ ប៉ុន្តែយល់ស្របដាក់បន្ថែមការចោទប្រកាន់អំពីការ សម្លាប់អតីតមន្ត្រី និងទាហានរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ក្រោយថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ក្នុងវិសាលភាពនៃសំណុំរឿង០០២/០១[3]។

4. កាលពីថ្ងៃទី ២២ ខែ កុម្ភៈឆ្នាំ ២០១៣ មេធាវីការពារក្តី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងកោះ ហៅលោក [redacted] ជាសាក្សីបញ្ជាក់ពីអត្តចរិក តាមសំណើរបស់នួន ជា[4]។

5. កាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ មេធាវីការពារក្តី ដាក់សេចក្តីជំទាស់ទៅនឹងសំណើរបស់ សហព្រះរាជអាជ្ញាស្នើសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីជាភស្តុតាង។ មេធាវី ការពារក្តី បានជំទាស់ទៅនឹងភស្តុតាងណាទាក់ទងគោលនយោបាយដែលត្រូវបានចោទប្រកាន់អំពី ការផ្តោតគោលដៅអតីតទាហាន និងមន្ត្រីសាធារណរដ្ឋខ្មែរ និងរក្សាសិទ្ធិរបស់ខ្លួនជំទាស់ទៅនឹង ភស្តុតាងទាក់ទងនឹងមូលដ្ឋាននៃបទឧក្រិដ្ឋពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ដែលកំពុងរង់ចាំការផ្តល់ សក្ខីកម្មដោយផ្ទាល់លើកម្មវត្ថុនោះ និងត្រូវបានគ្រោងពេលក្នុងសប្តាហ៍បន្ទាប់[5]។ ក្នុងអំឡុង

---

[1] សំណើទាំងនេះ ត្រូវបានផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់តាមរយៈសារអេឡិចត្រូនិក ប៉ុន្តែក្រោយមកត្រូវបានដាក់ភ្ជាប់នឹងសំណើមួយផ្សេងទៀត។ *សូមមើល* ឯកសារលេខ **E-189/3/1/7.1.5,** សំណើសុំសាក្សីបន្ថែម ថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ២០១២, កថាខណ្ឌ ៣២-៣៥។

[2] ឯកសារលេខ **E-236/1,** អនុស្សរណៈពីលោកចៅក្រម និល ណុន ផ្ញើជូនភាគីទាំងអស់ សំណុំរឿង០០២ ថ្ងៃទី ២ ខែ តុលា ឆ្នាំ ២០១២។

[3] ឯកសារលេខ **E-163/5,** អនុស្សរណៈពីលោកចៅក្រម និល ណុន ផ្ញើជូនភាគីទាំងអស់ សំណុំរឿង០០២ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២, កថាខណ្ឌ ៣។

[4] ឯកសារ **E-236/5/1,** "សំណើសុំកោះហៅសាក្សី TCW-223 ដែលពាក់ព័ន្ធនឹងអត្តចរិតរបស់នួន ជា" ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

[5] *សូមមើលផងដែរ* ឯកសារលេខ **E-223/2/8/1.2,** "ឧបសម្ព័ន្ធ ១- ការជំទាស់របស់នួន ជា ទៅនឹងបញ្ជីឯកសារ អនុលោមតាមវិធាន ៨០ (៣) (ឃ) របស់សហព្រះរាជអាជ្ញា-ឧបសម្ព័ន្ធ១២",*សូមមើលផងដែរ* ឯកសារលេខ **E-223/2/8,** "ការជំទាស់ទៅនឹងសំណើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និង

សប្តាហ៍នៃថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៣ អ៊ុង ឆាត់ និង លឹម សាត ជាសាក្សីចំនួនពីររូប ប៉ុណ្ណោះ ដែលអង្គជំនុំជម្រះសាលាដំបូង បានកោះហៅឲ្យមកផ្តល់សក្ខីកម្មទាក់ទងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃ មានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។

6. កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយស្តីពីការរៀបចំកាលវិភាគសម្រាប់កិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣។ អង្គជំនុំជម្រះសាលាដំបូង កត់សម្គាល់ថាពេលឆាប់ៗខាងមុខនេះ អង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្តីសម្រេចចុងក្រោយមួយលើសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង០០២/០១ និងសម្រេចថាភាគី នឹងមានឱកាសចុងក្រោយដើម្បីលើកឡើងនូវបញ្ហាថ្មីពិតប្រាកដពាក់ព័ន្ធនឹងសាក្សីនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ[6]។ កាលពីថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣ មន្ត្រីច្បាប់ជាន់ខ្ពស់ បានផ្ញើសេចក្តីសម្រេចចុងក្រោយមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសាក្សី។ សេចក្តីសម្រេចនោះ កត់សម្គាល់ពីសំណើរបស់មេធាវីការពារក្តីដែលស្នើឲ្យកោះហៅលោក ហេង សំរិន ជាសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជន និងជាសាក្សីបញ្ជាក់ពីអត្តចរិក តាមសំណើរបស់ខ្លួន ជា និងបញ្ជាក់ថាអង្គជំនុំសាលាដំបូង "មិនមានការព្រមព្រៀងគ្នាថាតើគប្បីកោះហៅគាត់ឬយ៉ាងណា[7]" ។

## II. ច្បាប់

## ក. បទដ្ឋានសម្រាប់ការទទួលយកភ័ស្តុតាង

7. អនុលោមតាមយុត្តិសាស្ត្រនៃអង្គជំនុំជម្រះនេះ ភាគីអាចស្នើដាក់ភ័ស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលសវនាការ នៅពេលភ័ស្តុតាង បំពេញលក្ខខណ្ឌ មានចែងក្នុងវិធាន ៨៧ (៤)។ ភាគីត្រូវបង្ហាញថាភ័ស្តុតាងអាចទទួលយកបានអនុលោមតាមវិធាន ៨៧ (៣) និង "ភ័ស្តុតាងនេះពុំមាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។ អង្គជំនុំជម្រះ បានធ្វើការបកស្រាយដោយមានភាពបត់

ប្រតិចារិក", ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣, ឯកសារលេខ **E-223/2/8/1** "ឧបសម្ព័ន្ធបន្ថែមពាក់ព័ន្ធនឹងការជំទាស់ទៅនឹងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារឹកនានា" ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣។

[6] ឯកសារលេខ **E-288**, អនុស្សរណៈពីលោកចៅក្រម និល ណុន ផ្ញើជូនភាគីទាំងអស់, ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣, កថាខណ្ឌ៣។

[7] "ឧបសម្ព័ន្ធ II - បុគ្គលដែលត្រូវបានស្នើដោយភាគីពាក់ព័ន្ធនឹងសំណុំរឿង០០២/០១ ប៉ុន្តែមិនបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ" ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០១៣, ទំព័រ៤។

បែននូវវិធាន ៨៧ (៤) និងទទួលយកភ័ស្តុតាងណាដែលមានតម្លៃជាភ័ស្តុតាង[8]។ នៅពេល ភាពជាប់ទាក់ទងនៃភ័ស្តុតាង អាចមើលឃើញច្បាស់ក្នុងអំឡុងពេលសវនាការ អង្គជំនុំជម្រះ គប្បីពិចារណាបន្ថែមថា ភ័ស្តុតាងនោះ ពីមុន "មិនអាចរកបានទេ" ដោយអនុលោមវិធាន ៨៧ (៤)។

## ខ. ភាពអាចទទួលយកបាននៃកំណត់ហេតុស្តាប់ចម្លើយសាក្សី

8. មេធាវីការពារ បានដាក់សារណាលម្អិតពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្តិ ដែលអាចអនុវត្តបានចំពោះការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី ដែលដាក់បញ្ចូលនៅទីនេះជាឯកសារយោង[9]។ ដូចអង្គជំនុំជម្រះបានបញ្ជាក់រួចហើយ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយ ដែលមិនទាក់ទងនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទ ជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ ផ្អែកលើការពិចារណាលើកត្តាផ្សេងៗទៀត។ កត្តាទាំងនោះ រួមមានថាតើភ័ស្តុតាងនោះ មានលក្ខណៈត្រួតគ្នាទៅនឹងសក្ខីកម្មដោយផ្ទាល់ក្នុងសវនាការ ហើយវាត្រូវជំទាស់ដោយភាគីដែរឬទេ[10]។ ដូចមេធាវីការពារបានជំទាស់ពេលកន្លងមក នៅតុលាការ *មិនអចិន្ត្រៃយ៍* នានា កត្តាទីពីរនេះ ជាប់ទាក់ទងទៅនឹងសេចក្តីសម្រេចក្នុងការទទួលយកចម្លើយជាភ័ស្តុតាង *និង*សេចក្តីសម្រេចថាតើត្រូវមានការសួរដេញដោលដែរឬទេ[11]។ សហព្រះរាជអាជ្ញា យល់ស្របថាបញ្ជីនៃកត្តានានា ទាក់ទិននឹងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូងថាតើត្រូវទទួលយកកំណត់ហេតុស្តាប់ចម្លើយឬយ៉ាណានោះ គឺមិនមែនជាបញ្ជីពេញលេញទាំងស្រុងនោះទេ[12]។

---

[8] ឯកសារលេខ **E-266/3**, អនុស្សរណៈពីលោកចៅក្រម និល ណុន ផ្ញើជូនភាគីទាំងអស់, ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០១៣, កថាខណ្ឌ៣។

[9] ឯកសារលេខ **E-96/8/1**, "ការឆ្លើយតបជាបឋមទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិក", ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ២០១២ (សំណើបឋមសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ), កថាខណ្ឌ ៦-១៦, ឯកសារលេខ **E-223/2/8** ," សេចក្តីជំទាស់ទៅនឹងសំណើបន្ថែមរបស់សហព្រះរាជអាជ្ញាសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនូវកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី និងប្រតិចារិក", ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ("សេចក្តីជំទាស់ទៅនឹងសំណើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ"), កថាខណ្ឌ ៦-១៥។

[10] សំណើបឋមសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ, កថាខណ្ឌ ១២-១៣, សេចក្តីជំទាស់ទៅនឹងសំណើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ, កថាខណ្ឌ ៦-៧,១៤។

[11] សេចក្តីជំទាស់ទៅនឹងសំណើសុំឲ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយ, កថាខណ្ឌ ១៤។

[12] ឯកសារលេខ **E-277/1**, "ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាទៅនឹងសេចក្តីជំទាស់របស់មេធាវីការពារក្តីចំពោះការទទួលយកកំណត់ហេតុសាក្សី ពាក្យបណ្តឹង និងប្រតិចារិក"។

## III. សក្ខីកម្មរបស់ អ៊ុង ឆាត់ និង លឹម សាត

9. ដូចបានលើកឡើងក្នុងដីកាដំណោះស្រាយ ហើយបច្ចុប្បន្នស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ នួន ជា ប្រឈមនឹងបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់នៅទីកន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ បន្ទាប់ពីខេត្តពោធិ៍សាត់ និងតំបន់ទួលពោធិ៍ព្រៃ ត្រូវបានរំដោះ នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ១៩៧៥[13]។ ការទទួលខុសត្រូវខាងព្រហ្មទណ្ឌត្រូវបានចោទប្រកាន់ ក្នុងនោះរួមមាន តាមរយៈការចូលរួមរបស់គាត់ក្នុងគោលនយោបាយបក្សកុំម្មុយនីស្តកម្ពុជាក្នុងការផ្តោតគោលដៅលើអតីតមន្ត្រីសាធារណរដ្ឋខ្មែរ[14]។

10. ពីថ្ងៃទី ២៩ ខែ មេសា ដល់ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣ សាក្សី អ៊ុង ឆាត់ និង លឹម សាត ត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងការចោទប្រកាន់ទាំងនេះ។ សក្ខីកម្មនោះ មានសារៈសំខាន់បំផុត ដោយសារសក្ខីកម្មនោះ ត្រូវបានផ្តល់ដោយសាក្សីចំនួនពីររូប ប៉ុណ្ណោះដែលអង្គជំនុំជម្រះសាលាដំបូងបានកោះហៅ។ សក្ខីកម្មរបស់ពួកគាត់ នៅចំពោះមុខ ក.ស.ច.ស ផ្តល់ការគាំទ្រយ៉ាងខ្លាំងក្លាបំផុត (ហើយពេលខ្លះ ផ្តល់ការគាំទ្រទាំងស្រុង) ចំពោះការចោទប្រកាន់សំខាន់ៗបំផុតនៅក្នុងដីកាដំណោះស្រាយទាក់ទងនឹងទួលពោធិ៍ជ្រៃ[15]។

11. សក្ខីកម្មនេះ បង្ហាញថាសាក្សីទាំងពីរនេះជាកម្មាភិបាលថ្នាក់ទាបដែលមិនដឹងឮដោយផ្ទាល់អំពីអង្គហេតុសំខាន់ៗឡើយ[16]។ សាក្សីទាំងពីររូបនេះ មិនមានវត្តមានក្នុងកិច្ចប្រជុំរួមនៅក្នុងខេត្ត និងមិនបានដឹងឮដោយផ្ទាល់អំពីអ្វីដែលបានលើកឡើងក្នុងពេលនោះទេ[17]។ សាក្សីទាំងពីររូប មិនបានឃើញផ្ទាល់ភ្នែកនូវការសម្លាប់ដែលបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ និងផលវិបាកក្រោយការ

---

[13] ឯកសារលេខ **D-427**, "ដីកាដំណោះស្រាយ" ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ ៦៩៨-៧១១។

[14] ដីកាដំណោះស្រាយ,កថាខណ្ឌ ២០៥-២០៩។

[15] ដីកាដំណោះស្រាយ,កថាខណ្ឌ ៦០៨-៧១១។

[16] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 55:23-56:2។

[17] ឯកសារលេខ **E-1/186.1**, សក្ខីកម្មរបស់ អ៊ុងឆាត់, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 65:8-66:7, ឯកសារលេខ **E- E-1/187.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី", ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 23:4-24។

ការសម្លាប់នោះដែរ[18]។ វាផ្ទុយពីកំណត់ហេតុស្តាប់ចម្លើយអ៊ុង ឆាត់ ដែលបញ្ជាក់ថាគាត់បានឃើញផ្ទាល់ភ្នែកសាកសពមន្ត្រី ដែលទើបត្រូវបានសម្លាប់ថ្មីៗ[19]។ ក្នុងអំឡុងពេលសួរដេញដោលទើប អ៊ុង ឆាត់ បានដកពាក្យរបស់គាត់ ដោយនិយាយថាគាត់មិនដែលបានឃើញសាកសពនោះឡើយ[20] ប៉ុន្តែគាត់បានឃើញតែ "ទីកន្លែងដែលសាកសពមួយ អាចត្រូវបានកប់នៅទីនោះ"។[21]

12. សាក្សីទាំងពីររូបនោះ មិនអាចផ្ទៀងផ្ទាត់ចំនួនមន្ត្រីសាធារណរដ្ឋខ្មែរដែលត្រូវបានអះអាងថាត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃទេ។ ចម្លើយរបស់ លឹម សាត ជាចម្លើយតែមួយគត់ដែលផ្តល់ការគាំទ្រនៅក្នុងដីកាដំណោះស្រាយចំពោះការចោទប្រកាន់ថាអតីតទាហាន លន់ នល់ ចំនួនបីពាន់នាក់ត្រូវបានដឹកទៅសម្លាប់នៅទួលពោធិ៍ជ្រៃ[22] បានផ្តល់សក្ខីកម្មថា "គាត់មិនបានចាប់អារម្មណ៍រាប់ចំនួនមនុស្សទេ ពីព្រោះ[គាត់]មានភារកិច្ចត្រឹមតែយាមនៅកន្លែងនោះតែប៉ុណ្ណោះ[23]"។ គាត់មិនមានព័ត៌មានគួរឲ្យជឿជាក់អំពីចំនួនរថយន្តដែលត្រូវបានប្រើដើម្បីដឹកជនរងគ្រោះទៅកាន់ទួលពោធិ៍ជ្រៃ និងមិនអាចធ្វើការគណនាគណិតវិជ្ជាជាមូលដ្ឋានដែលចាំបាច់ក្នុងការវាយតម្លៃឲ្យបានត្រឹមត្រូវអំពីចំនួនអតីតមន្ត្រី លន់ នល់ ដែលត្រូវបានដឹកជញ្ជូនឡើយ[24]។ គាត់មិនដឹងថាមានមនុស្សចំនួនប៉ុន្មាននាក់បានចូលរួមក្នុងកិច្ចប្រជុំរួមទេ[25]។ អ៊ុង ឆាត់ លើកឡើងថាមានមនុស្សចំនួនប្រហែល២០០នាក់

---

[18] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 84:11-18, 85:20-24។ ឯកសារលេខ **E-1/187.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 73:22-74, 51:11-13។

[19] ឯកសារលេខ **D-125/176**, កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុង ឆាត់ លើកទី១, ទំព័រ៥។

[20] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 22:21-25, 25:21-25។

[21] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 85:20-24។

[22] ដីកាដំណោះស្រាយ កថាខណ្ឌ ៧០៨, ជើងទំព័រ៣០៤៩។

[23] ឯកសារលេខ **E-1/187.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 84:23-25។

[24] ឯកសារលេខ **E-1/187.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 72:20-73:19, 84:18-85:4, 84:18-25។

[25] ឯកសារលេខ **E-1/187.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 55:23-56:2។ ឯកសារលេខ **E-1/188.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 24:14-21។

បានចូលរួម[26]។

13. សក្ខីកម្មដែលផ្តល់នៅសវនាការ ក៏បានបញ្ជាក់ថាមិនមានសាក្សីណាម្នាក់ បានដឹង ឬមានឱកាសធ្វើការសង្កេតអំពីបុណ្យស័ក្តិ និងឋានៈរបស់ជនរងគ្រោះទាំងនោះឡើយ[27]។ នៅពេលសួរតទល់នឹងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ជាមួយ ក.ស.ច.ស សាក្សីនិយាយថា "អ្នកដែលចាកចេញពីសាលាខេត្តជាឧត្តមសេនីយ៍យោធាលន់ នល់[28]"។ អ៊ុំង ឆាត់ ផ្តល់សក្ខីកម្មថាពាក្យ "ឧត្តមសេនីយ៍" មិនមែនជាពាក្យរបស់គាត់ទេ ប៉ុន្តែជាពាក្យរបស់អ្នកស៊ើបអង្កេត ក.ស.ច.ស[29]។គាត់ "មិនអាចនិយាយបានថាតើអ្នកទាំងនោះពាក់ស័ក្តិប៉ុន្មានទេ[30]" ហើយ "គាត់មិនដឹងពីស័ក្តិ និងឋានៈរបស់ពួកគេដែរ[31]"។ ការលើកឡើងរបស់គាត់ដែលថាមន្ត្រីយោធាជាន់ខ្ពស់មានវត្តមាន ផ្អែកទាំងស្រុងលើការឃើញមនុស្សម្នាក់គត់ដែលគាត់ជឿជាក់ថា មានលក្ខណៈសមស្របក្នុងការពិពណ៌នាដូច្នោះ[32]។ ទោះជាយ៉ាងនេះក្តី សាក្សីទាំងពីររូបនេះ បានផ្តល់សក្ខីកម្មថាអ្នកទាំងឡាយដែលបានចូលរួមក្នុងកិច្ចប្រជុំនោះ ជាមន្ត្រីមូលដ្ឋានក្នុងខេត្តពោធិ៍សាត់[33]។ យោងតាមលឹម សាត អ្នកចូលរួមដែលមានចំនួន១០០នាក់ ពីមុនជាកូនទាហានដែលបោះទីតាំងនៅបន្ទាយទួលពោធិ៍ជ្រៃ មុនពេលបន្ទាយនោះ

---

[26] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 58:3-8, 73:1-3។

[27] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 78:6-17។ ឯកសារលេខ **E-1/188.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 12:21-13:4 (លឹម សាត បានផ្តល់សក្ខីកម្មថាគាត់បានសង្កេតឃើញទាហានលន់ នល់ ពាក់ឯកសណ្ឋាន ប៉ុន្តែគាត់បានកំណត់សក្តិរបស់ទាហានយ៉ាងជាក់លាក់បំផុត។)

[28] ឯកសារលេខ **D-125/176**, កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុំង ឆាត់, ទំព័រ៣។

[29] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 77:24-78-17។

[30] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 78:2-5។

[31] *ដូចជើងទំព័រខាងលើ*

[32] ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 3:16-19។

[33] ឯកសារលេខ **E-1/188.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣ ខែ ឧសភា ឆ្នាំ ២០១៣, ទំព័រ 28:1-16។ ឯកសារលេខ **E-1/186.1**, "ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)", ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣, ទំព័រ 74:21-25។

ធ្លាក់ក្នុងដៃរបស់កម្លាំងខ្មែរក្រហម[34]។

14. ដោយហេតុថាមិនមានការដឹងផ្ទាល់អំពីអ្វីដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ អត្តសញ្ញាណ ឬចំនួនជនរងគ្រោះនៅទីនោះ ឬអត្ថិភាពនៃគោលនយោបាយដែលត្រូវបានចោទប្រកាន់អំពីការសម្លាប់មន្ត្រីសាធារណរដ្ឋខ្មែរនោះ សំណួរថាតើការកាប់សម្លាប់ដែលត្រូវបានចោទប្រកាន់ ជាផ្នែកមួយនៃគោលនយោបាយធំរបស់បក្សកុំមុយនីស្តកម្ពុជាឬយ៉ាងណា ស្ថិតនៅឆ្ងាយពីវិសាលភាពនៃការដឹងរបស់សាក្សីទាំងពីររូប។

## IV. ទន្និករណ៍

### ក. អង្គជំនុំជម្រះសាលាដំបូង ត្រូវកោះហៅសាក្សីទាំងអស់ ដែលក.ស.ច លើកយកមកសំអាងទាក់ទងនឹងទួលពោធិ៍ជ្រៃ

15. មេធាវីការពារក្តី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងកោះហៅសាក្សីដែលនៅសេសសល់ ដែល ក.ស.ច លើកយកមកសំអាងទាក់ទងនឹងទួលពោធិ៍ជ្រៃដើម្បីគាំទ្រការចោទប្រកាន់លើអង្គហេតុពាក់ព័ន្ធនឹង៖ [redacted], [redacted], [redacted], [redacted] និង [redacted] (សាក្សីទាក់ទងនឹងទួលពោធិ៍ជ្រៃ)។ ការសួរដេញដោលសាក្សីទាំងប្រាំរូបនេះដោយផ្ទាល់ ក្នុងពេលសវនាការ នឹងបញ្ជាក់បន្ថែមថាភស្តុតាងពាក់ព័ន្ធនឹងអង្គហេតុសំខាន់ៗ មិនអាចជឿជាក់បាន និងមិនស៊ីសង្វាក់គ្នា ហើយអង្គជំនុំជម្រះសាលាដំបូង មិនអាចសម្រេចថាភស្តុតាងនោះហួសពីវិមតិសង្ស័យបានឡើយ។

i. សាក្សីទាក់ទងនឹងទួលពោធិ៍ជ្រៃ

16. សាក្សីទាក់ទងនឹងទួលពោធិ៍ជ្រៃទាំងប្រាំរូប បានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត។

17. កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] បញ្ជាក់ថាសាក្សីបានឃើញរថយន្តចំនួន១០០

[34] ឯកសារលេខ E-1/188.1, “ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធី (ភាសាអង់គ្លេស)”, ទំព័រ 29:22-30:3 (ទាហានលន់ នល់មកពីបន្ទាយនៃទួលពោធិ៍ជ្រៃ ត្រូវបានយកមកចូលរួមកិច្ចកិច្ចប្រជុំរួមក្នុងខេត្តពោធិ៍សាត់ និងក្រោយមកត្រូវបានអះអាងថាត្រូវបានខ្មែរក្រហមសម្លាប់។)

ដឹកអតីតមន្ត្រីយោធាសាធារណរដ្ឋខ្មែរ អភិបាលខេត្ត និងមន្ត្រីរដ្ឋការទៅកាន់ទួលពោធិ៍ជ្រៃ[35]។ គាត់ប៉ាន់ស្មានថាមនុស្សចំនួន ៣០០ នាក់ ត្រូវបានសម្លាប់នៅទួលពោធិ៍ជ្រៃ ផ្អែកលើចំនួនរថយន្ត ដែលគាត់បានសង្កេតឃើញ និងព័ត៌មានដែលគាត់បានឮពីអ្នកដទៃ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីរូបនេះ បង្ហាញថាសាក្សីបានត្រឡប់មកទួលពោធិ៍ជ្រៃក្នុងឆ្នាំ១៩៨៦ និងបានឃើញសាកសព និងរណ្តៅកប់សាកសព។

18. កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ពិពណ៌នាអំពីកិច្ចប្រជុំរួមក្នុងខេត្តពោធិ៍សាត់ ដែលមានមនុស្សចំនួន ៥០០ នាក់ បានចូលរួម[36]។ អ្នកចូលរួម ត្រូវបានដឹកតាមរថយន្តចំនួន១៣-១៥ ដែលធ្វើដំណើរច្រើនជាងមួយជើងទៅកាន់ទួលពោធិ៍ជ្រៃ។ គាត់បានដឹងថាអ្នកដែលត្រូវបានយកទៅទួលជើងព្រៃ ត្រូវបានសម្លាប់បីថ្ងៃក្រោយមក។

19. កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] បញ្ជាក់ថាសាក្សីបានឃើញទាហានខ្មែរក្រហម "ប្រមូល" មនុស្សឱ្យជួបជុំគ្នានៅស្នាក់ការធំខេត្តពោធិ៍សាត់ និងបានឃើញអភិបាលខេត្តចូលរួមក្នុងកិច្ចប្រជុំនោះ[37]។ សាក្សី មិនបានចូលរួមក្នុងកិច្ចប្រជុំនោះទេ, មិនបានដឹងថាអ្នកណារៀបចំកិច្ចប្រជុំនោះ ឬកិច្ចប្រជុំនោះនិយាយអំពីអ្វី ឬមិនបានឃើញអ្នកចូលរួមត្រូវបានយកចេញឡើយ។ សាក្សីបានឮពេលក្រោយថាពួកគេត្រូវបានសម្លាប់។

20. កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ពិពណ៌នាអំពីសេចក្តីប្រកាសថាមន្ត្រីយោធាសាធារណរដ្ឋខ្មែរដែលមានឋានន្តរស័ក្តិចាប់ពីអនុសេនីយ៍ត្រី ដល់វរសេនីយ៍ឯក នឹងត្រូវប្រមូលយកទៅរៀនសូត្រនៅអង្គរវត្ត និងបន្ទាប់មកត្រូវដំឡើងស័ក្តិ[38]។ សាក្សី បញ្ជាក់ថាទាហាន ត្រូវបានដឹកតាមរថយន្តដែលមានចំនួនប្រហែល៤០នាក់ទៅទួលពោធិ៍ជ្រៃ ជាកន្លែងដែលពួកគេត្រូវបានសម្លាប់។ គាត់បានដឹងពីការសម្លាប់នៅថ្ងៃបន្ទាប់ និងបានឃើញសាកសពនៅពេលក្រោយមកទៀត។

21. កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted] ពិពណ៌នាអំពីរថយន្តដឹកទាហានសាធារណរដ្ឋខ្មែរដែល

---

[35] ឯកសារលេខ **D-125/49**, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted], ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ២០០៨។

[36] ឯកសារលេខ **D-125/48**,, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted],ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៨។

[37] ឯកសារលេខ **D-232/13**, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted], ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៩។

[38] ឯកសារលេខ **D-125/175**, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted], ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០០៩។

ពាក់ឯកសណ្ឋាន និងគ្រឿងសម្គាល់យោធា[39]។ រថយន្តនីមួយៗ ដឹកមនុស្សចំនួនប្រហែល៣០នាក់ ប៉ុន្តែសាក្សីមិនបានឈប់មើលរថយន្តទាំងនោះទេ។ ថ្ងៃបន្ទាប់ គាត់សង្កេតឃើញស្នាមកង់រថយន្ត ឈូសពង្រាបដីពីចម្ងាយ ប៉ុន្តែគាត់មិនបានឃើញសាកសព និងការសម្លាប់ទេ។

## ii. ការសួរដេញដោលសាក្សីទួលពោធិ៍ជ្រៃ នឹងដោះបន្ទុក នួនជា

22. ដូចគ្នាលឹម សាត និង អ៊ុង ឆាត់ ដែរ ក្នុងចំណោមសាក្សីទាំងនេះ មិនមានសាក្សីណាបានឃើញការសម្លាប់ដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃឡើយ។ កំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ លើកឡើងថា [redacted] និង [redacted] បានឃើញសាកសពនៅទីកន្លែងសម្លាប់មនុស្សនៅពេលក្រោយ ដូចគ្នានឹងអ៊ុង ឆាត់ ដែរ ដែលគាត់បានកែតម្រូវកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ក្នុងពេលសវនាការ[40]។ សហចៅក្រមស៊ើបអង្កេត មិនដែលបានធ្វើការស៊ើបអង្កេតកោសល្យវិច័យ ឬខ្នះខ្នែងគាស់កាយសាកសពដែលបានចោទប្រកាន់ថាត្រូវបានកប់នៅទីនោះឡើយ[41]។ គ្មានភ័ស្តុតាងបង្ហាញពីការសម្លាប់មនុស្សណាមួយនៅទួលពោធិ៍ជ្រៃឡើយ។

23. អង្គហេតុដែលសាក្សីរូបនេះបានអះអាងថា មានការដឹងដោយផ្ទាល់នោះ គឺមិនស៊ីចង្វាក់គ្នា និងមិនអាចឲ្យជឿបានឡើយ។ ការប៉ាន់ប្រមាណរបស់ [redacted] ថាមានមនុស្សចំនួន ៣.០០០ នាក់ត្រូវបានគេសម្លាប់នោះ ត្រូវបានសម្អាងទៅលើវិធីសាស្ត្រមិនច្បាស់លាស់ដូចគ្នានេះដែរ ដោយការរាប់ចំនួនរថយន្តធំដែលបើកឆ្លងកាត់ដោយត្រួសៗ ដែលបានធ្លាក់មកលើការសួរដេញដោលដោយមេធាវីការពារក្តីចំពោះ លឹម សាត។ [redacted] បានផ្តល់សក្ខីកម្មថា មនុស្សចំនួន ៥០០ នាក់បានចូលរួមប្រជុំនៅឯសាលាខេត្ត ប៉ុន្តែ ស.ច.ស បានសន្និដ្ឋានថា ចំណុះជាអតិប្បរមានៃបន្ទប់នោះអាចដាក់មនុស្សបានចំនួន ២០០ នាក់[42]។ វាក៏មិនច្បាស់លាស់ទេថា [redacted] ពិតជាបានចូលរួមក្នុងកិច្ចប្រជុំមែននោះ ហើយប្រសិនបើបានចូលរួមប្រជុំមែននោះ ថាតើគាត់ (ដែលជាទាហាន សាធារណរដ្ឋខ្មែរ) អាចរស់រានមានជីវិតដោយរបៀបណានោះ។ [redacted] អះអាងថា រថយន្តធំចំនួន ១០០ គ្រឿងបានចេញដំណើរតែមួយលើក ចំណែកឯ [redacted] វិញ

---

[39] ឯកសារលេខ **D-125/174**, កំណត់ហេតុស្តាប់ចម្លើយសាក្សី [redacted], ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០០៩។

[40] *សូមមើល* កថាខណ្ឌ ១, ដូចខាងលើ។

[41] ឯកសារលេខ **D-125/217**, របាយការណ៍កមណត់អត្តសញ្ញាណទីតាំង ទួលពោធិ៍ជ្រៃ, ទំព័រ ៣។

[42] ឯកសារលេខ **D-125/217** របាយការណ៍កំណត់អត្តសញ្ញាណទីពិឃាតទួលពោធិ៍ជ្រៃ ត្រង់ទំព័រទី ១០។

នៅចាំថា ឡានធំចំនួន ១៣ គ្រឿងបានធ្វើដំណើរជាច្រើនលើក។ ក្រៅពី [redacted] ពុំមានសាក្សីណាម្នាក់និយាយថា ឡានធំទាំងនោះអាចធ្វើដំណើរចេញពីសាលាខេត្តទៅកាន់ទីតាំងឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់ និងបានត្រឡប់មកវិញនោះទេ។

24. [redacted] និង [redacted] លើកឡើងថា ជនរងគ្រោះទាំងនោះគឺជាទាហាន ចំណែកឯ [redacted] វិញនៅចាំបានថា មានទាហាន និងអ្នករដ្ឋការចម្រុះគ្នា។ [redacted] និង លឹម សាត នៅចាំបានថា ពួកទាហានទាំងនោះស្លៀកពាក់ឯកសណ្ឋានទាហាន ប៉ុន្តែ អ៊ុំង ឆាត់ បានលើកឡើងដែលៗថា "ពួកគេទាំងអស់ស្លៀកពាក់ខោអាវស៊ីវិលទេ"[43]។ [redacted] បានអះអាងថា ពួកកងទ័ពខ្មែរក្រហម "បានប្រមូលផ្តុំ" ជនរងគ្រោះទាំងនោះដើម្បីដឹកទៅកាន់សាលាខេត្ត ប៉ុន្តែ អ៊ុំង ឆាត់ បានផ្តល់សក្ខីកម្មថា ពួកគេបានធ្វើដំណើរមកដល់សាលាខេត្តដោយស្ម័គ្រចិត្តទេ[44]។

25. ភាពស្រពេចស្រពិលទាក់ទងនឹងអង្គហេតុទាំងនេះ វាសំខាន់ចំពោះករណី (អាចជាភស្តុតាងដោយប្រយោលបំផុត) ដែលថា នួន ជា ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការសម្លាប់នៅទួលពោធិ៍ជ្រៃ។ ការមិនមានភស្តុតាងដោយផ្ទាល់ថា គោលនយោបាយ ប.ក.ក ដើម្បីសម្លាប់ទាហាន និងមន្ត្រីរដ្ឋការរបបសាធារណរដ្ឋខ្មែរពិតជាមាន ឬថាការសម្លាប់នៅទួលពោធិ៍ជ្រៃបានកើតឡើង នោះចំនួន ឋានន្តរស័ក្តិ និងប្រភពដើមនៃជនរងគ្រោះទាំងនោះ គឺជាចំនុចគន្លឹះដើម្បីធ្វើការវាយតម្លៃទៅលើការទទួលខុសត្រូវរបស់ នួន ជា។ ដូចគ្នានេះផងដែរចំពោះធម្យោបាយដែលជនរងគ្រោះទាំងនេះបានមកដល់សាលាខេត្ត។ អ្នកជំនាញរបស់សហព្រះរាជអាជ្ញាផ្ទាល់បានសន្និដ្ឋានទាំងខុស និងមិនមានមូលដ្ឋានថា មានតែនាយទាហានជាន់ខ្ពស់ និងអ្នករដ្ឋការដែលមានឋានៈខ្ពង់ខ្ពស់តែប៉ុណ្ណោះត្រូវបានគេសម្លាប់ចោល[45]។ ប៉ុន្តែ ភស្តុតាងបង្ហាញថា ប្រសិនបើពិតជាមានការសម្លាប់

[43] ឯកសារលេខ **E-1/186.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ១៣:៦-៩។

[44] ឯកសារលេខ **E-1/186.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៥៦:១៧-៥៧:២។ ឯកសារលេខ **E-1/185.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី 29 ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៨១:១-៤។

[45] ឯកសារលេខ **IS20.6** កិច្ចសម្ភាសន៍របស់លោក Steve Heder ជាមួយ អៀង សារី នៅថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ១៩៩៦ ទំព័រទី ៦ [យោងតាមលោក Steve Heder "ឯកសារនោះមិនបានបញ្ជាក់ច្បាស់ថា អ្នកដែលត្រូវបានគេសម្លាប់ទាំងនោះរួមមាន នាយទាហាន នាយទាហានជាន់ខ្ពស់ (ភ្នាក់ងារសម្ងាត់) និងប្រភេទដទៃទៀត ប៉ុន្តែ មិនមែនកូនទាហានធម្មតា និងអ្នករដ្ឋការតូចតាច ដូចជា គ្រូបង្រៀន នោះទេ"]។ ឯកសារលេខ **E-1/191.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ" ចុះថ្ងៃទី ៨

នៅទួលពោធិ៍ជ្រៃនៅក្រោយថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៧៥ មែន នោះជនរងគ្រោះទាំងនោះ គឺជាបណ្ដុំនៃកូនទាហានធម្មតា និងមន្ត្រីរដ្ឋការតូចតាច ដែលត្រូវបានកោះហៅដោយគ្មានរបៀបរៀបរយឱ្យមកកាន់សាលាខេត្តដោយអាជ្ញាធរមូលដ្ឋាន។ សេចក្ដីសន្និដ្ឋានដែលសមហេតុផលតែមួយគត់គឺ អាជ្ញាធរមូលដ្ឋានទាំងនោះបានប្រព្រឹត្តឡើងដោយឯកឯង ដើម្បីសងសឹកចំពោះអតីតគូប្រជែងរបស់ខ្លួន។

26. មេធាវីការពារក្ដីកត់សម្គាល់ឃើញថា ការប្រៀបធៀបរវាងការចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ និងភស្តុតាងដែលបានបង្ហាញ ដើម្បីគាំទ្រការដល់ចោទប្រកាន់នៅក្នុងកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី គឺមិនស៊ីចង្វាក់គ្នាទាល់តែសោះ ដែលនាំឱ្យមានការមន្ទិលសង្ស័យទៅលើវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេត។ សហចៅក្រមស៊ើបអង្កេតបានស្ដាប់ឮការប៉ាន់ប្រមាណពីចំនួនជនរងគ្រោះដែលមានពី ២០០ នាក់ទៅ ៣.០០០ នាក់[46] បន្ទាប់មកបានសន្និដ្ឋានដោយមិនមានការកែប្រែថា មនុស្សចំនួនពី ២.០០០ នាក់ ទៅ ៣.០០០ នាក់ ត្រូវបានសម្លាប់[47]។ សហចៅក្រមស៊ើបអង្កេតបានធ្វើមិនដឹងមិនឮ ចំពោះសេចក្ដីសន្និដ្ឋានរបស់អ្នកស៊ើបអង្កេតរបស់ខ្លួនដែលថា មនុស្សមិនលើសពីចំនួន ២០០ នាក់ទេអាចមានវត្តមាននៅក្នុងសាលាខេត្ត[48] និងបានទទួលយកដោយមិនមានការចោទសួរទៅលើការវិភាគរបស់ លឹម សាត ដែលថា ដោយសារមានមនុស្សចំនួនពី ៣០ ទៅ ៤០ នាក់នៅក្នុងរថយន្តមួយគ្រឿង ក្នុងចំណោមរថយន្តធំចំនួន ៣០ គ្រឿង នោះត្រូវមានមនុស្សសរុបទាំងអស់ចំនួន ៣.០០០ នាក់[49]។ ដោយយោងទៅលើ

---

ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៤:២៤-៩៥:៣ (យោងតាមលោក Philip Short មន្ត្រីដែលមានឋានៈ "ខ្ពង់ខ្ពស់" គឺជាគោលដៅ។

[46] ឯកសារលេខ **D-125/176** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ុង ឆាត់ ទំព័រទី ៣។ ឯកសារលេខ **E-3/364** កំណត់ហេតុ នៃការស្ដាប់ចម្លើយសាក្សី លឹម សាត លើកទីមួយ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រទី ២។ ឯកសារលេខ **D-232/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សាត លើកទីពីរ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រទី ៤។ ឯកសារលេខ **D-125/49** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៨។ ឯកសារលេខ **D-125/48** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨។

[47] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៧១១។

[48] *សូមអាន* កថាខណ្ឌ ២៣ *ខាងលើ*។

[49] ឯកសារលេខ **E-3/364** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សាត លើកទីមួយ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២។ ឯកសារលេខ **D-232/65** កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី លឹម សាត លើកទីពីរ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ទំព័រ ៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កថាខណ្ឌ ៧០៨។

មូលដ្ឋាននៃការសម្អាងដែលមិនមានលក្ខណៈច្បាស់ នៅក្នុងកិច្ចសម្ភាសន៍តែមួយលើក សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋានតាមទំនើងចិត្ត ពីក្នុងចំណោមសន្និដ្ឋានជាច្រើន[50] ដែលថា រថយន្តធំពី ៣០ ទៅ ៤០ គ្រឿងបានដឹកជញ្ជូនមនុស្សពីសាលាខេត្តទៅកាន់ទីតាំងសម្លាប់មនុស្សដែលបានចោទប្រកាន់នេះ[51] និងបានសន្និដ្ឋានយ៉ាងច្បាស់លាស់ថា រថយន្តធំទាំងនោះបានដឹកជញ្ជូនមនុស្សជាច្រើនជើង[52]។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេត បានដាក់បញ្ចូលគ្នានូវសក្ខីកម្មរបស់សាក្សីមួយរូបដែលថា រថយន្តធំចំនួន ១៣ គ្រឿងបានដឹកជញ្ជូនជាច្រើនជើង ជាមួយនឹងសក្ខីកម្មរបស់សាក្សីម្នាក់ទៀតដែលថា មានរថយន្តធំចំនួនពី ៣០ ទៅ៤០ គ្រឿង ដើម្បីឈានដល់ការធ្វើសេចក្តីសន្និដ្ឋានថា រថយន្តធំចំនួនពី ៣០ ទៅ ៤០ គ្រឿង បានដឹកជញ្ជូនជាច្រើនជើងនោះ[53]។ អ្នកស៊ើបអង្កេតបានបំពេញបន្ថែមទៅលើសេចក្តីសន្និដ្ឋានរបស់ អ៊ុង ឆាត់ ថា "ថ្នាក់ឧត្តមសេនីយ៍" ក៏ស្ថិតនៅក្នុងចំណោមជនរងគ្រោះដែរ[54] រួចហើយបានសម្អាងទៅលើសក្ខីកម្មរបស់គាត់តាំងស្រុងដើម្បីរកឲ្យឃើញថា "សក្ខីកម្មរបស់សាក្សីគាំទ្រ"ដល់ទស្សនៈរបស់ខ្លួនដែលថា អតីតនាយ

---

[50] ឯកសារលេខ **D-125/49** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ ឯកសារលេខ **D-125/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨។ ឯកសារលេខ **D-125/176** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង ឆាត់ ទំព័រ ៣។ ឯកសារលេខ **E-3/364** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីម សាត លើកទីមួយ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២។

[51] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ កថាខណ្ឌ ៧០៩។

[52] ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧០៩ លេខយោងជើងទំព័រ ៣០៥៥។ ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះយោងទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង ឆាត់ និងសាក្សី [redacted] ចំពោះការអះអាងនេះ ប៉ុន្តែចម្លើយរបស់ អ៊ុង ឆាត់ មិនគាំទ្រដល់ការអះអាងនេះទេ។ កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សីរូបនេះគ្រាន់តែនិយាយថា ឡានដឹកជញ្ជូនទាហាន លន់ នល់ ឆ្លងកាត់ពីបន្ទាយភូមិពោធិ៍ឆ្ពោះទៅកាន់ទួលពោធិ៍ជ្រៃ ម្តងមួយក្នុងមួយពេល និងថាឡាននីមួយៗត្រូវរង់ចាំឡានមុនត្រឡប់មកវិញសិន ទើបឲ្យឡានមួយទៀតចេញទៅ។ មិនមានការបញ្ជាក់ថា ឡានដែលត្រឡប់មកវិញបានដឹកទាហានបន្ថែមទៀតទៅកាន់ទួលពោធិ៍ជ្រៃនោះទេ។ កសារលេខ **D-125/176** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុង ឆាត់ លើកទីមួយ ទំព័រ ៤ ដល់ ៥។

[53] ឯកសារលេខ **E-3/364** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លីម សាត លើកទីមួយ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ទំព័រ ២។ ឯកសារលេខ **D-125/48** កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី [redacted] ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០០៨។

[54] *សូមអាន* កថាខណ្ឌ ១៣ *ខាងលើ*។

តាហាន“ទាំងអស់”ត្រូវបានកោះហៅឲ្យមកចូលរួមក្នុងកិច្ចប្រជុំនោះ[55]។

27. ការដែលសំណើទាមទារឲ្យមានការសួរតទល់បានសូន្យនោះ បង្ហាញថា សហចៅក្រមស៊ើបអង្កេត មិនបានខិតខំប្រឹងប្រែងដើម្បីស្វែងរកការពិត ឬដើម្បីស៊ើបអង្កេតដោយឥតលម្អៀងនោះឡើយ។ ផ្ទុយទៅវិញ ស.ច.ស បានខិតខំស្វែងរកភស្តុតាងដាក់បន្ទុកយ៉ាងស្វិតស្វាញ នៅក្នុងអំឡុងនៃការស៊ើបអង្កេតរបស់ខ្លួន បន្ទាប់មកបានដកស្រង់យ៉ាងសម្រិតសម្រាំង យកចេញពីក្នុងចំណោមភស្តុតាងដែលមានលក្ខណៈលម្អៀង ដើម្បីបង្កើតជាដំណើររឿងទូទៅមួយដែលពុំដល់សភាពលក្ខណៈនៃអង្គហេតុទាំងនោះឡើយ។ “សច្ចធារណ៍” គតិយុត្តិនៃអនាគតិភាព និងភាពគួរឲ្យជឿជាក់បានពុំមានទម្ងន់នោះទេ ប្រសិនបើ អនាគតិភាព និងភាពគួរឲ្យជឿជាក់បាននេះត្រូវបានជំទាស់ទាំងស្រុងដោយតថភាពពិតនោះ។

28. ដោយសារតែពេលនេះ តម្រូវឲ្យអង្គជំនុំជម្រះធ្វើការសម្រេច នួន ជា មិនមានបំណងសម្អាងតែទៅលើអវត្តមាននៃភស្តុតាងប៉ុណ្ណោះទេ និងសូមជំទាស់ថា ពុំមានអង្គហេតុគួរឲ្យជឿជាក់ណាមួយអាចយកមកផ្តន្ទាទោសលើរូបគាត់ ដោយសម្អាងទៅលើមូលដ្ឋាននៃភស្តុតាងដែលមាននៅចំពោះមុខអង្គជំនុំជម្រះបានឡើយ។ គាត់មិនមានចេតនាលាក់បាំងបន្ទុកនៃការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញានោះឡើយ ហើយអង្គជំនុំជម្រះនេះក៏មិនគួរជួយលាក់បាំងការមិនបញ្ចេញការមិនបញ្ចេញភាពសម្ងាត់របស់ ស.ច.ស នោះដែរ។ នួន ជា ចង់បាន (ហើយតាមរយៈនេះស្នើសុំ) ឲ្យមានសវនាការសាធារណៈពេញលេញមួយ ដោយយោងទៅលើមូលដ្ឋាន ដែលទាំងអង្គជំនុំជម្រះ និងសាធារណជនអាចរៀបចំសេចក្តីសន្និដ្ឋានរបស់ខ្លួន ថាតើ នួន ជា ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មដែលចោទប្រកាន់ ថាបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃដោយរបៀបណាដែរនោះ។ សវនាការនោះនឹងបង្ហាញលើសពីស្រមោលនៃភាពមន្ទិលសង្ស័យ ដែលគាត់មិនមានការសន្ទិលសង្ស័យនោះទេ។

### iii – <u>សំណើសុំនេះ គឺជាបញ្ហាថ្មីសុទ្ធសាធ និងបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៤)</u>

---

[55] ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ កថាខណ្ឌ ៧០៦។ ដូចបានលើកឡើងខាងលើរួចមកហើយ អ៊ុំង ឆាត់ បានផ្តល់សក្ខីកម្មនៅក្នុងតុលាការថា នៅក្នុងចំណោមអ្នកដែលគេដឹកទៅកាន់ទួលពោធិ៍ជ្រៃនោះ គាត់មិនអាចញែកចេញពីគ្នាថាអ្នកណាជាទាហាន ឬអ្នកណាជាជនស៊ីវិលបានទេ ដោយសារពួកគេទាំងអស់ស្លៀកពាក់ស៊ីវិល ហើយហេតុផលដូចគ្នានេះដែរ គាត់មិនអាចដឹងពីឋានន្តរស័ក្តិរបស់ពួកគេបានទេ។ *សូមអាន* កថាខណ្ឌ ១៣ *ខាងលើ*។ ឯកសារលេខ **E-1/186.1** “ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ” ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៣ ទំព័រ ៣២:១៥-៣៣:២៥។

29. នៅក្នុងឆ្នាំ ២០១១ មិនមានសាក្សីទួលពោធិ៍ជ្រៃណាម្នាក់ ត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីរាយឈ្មោះសាក្សីរបស់មេធាវីការពារក្តីនោះទេ[56]។ ហេតុដូច្នេះ យោងតាមយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះនេះ មេធាវីការពារក្តីត្រូវបានតម្រូវឲ្យបំពេញលក្ខខណ្ឌនៃវិធាន ៨៧(៤)។ យោងតាមអនុស្សារណៈរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៣ ក៏មានការតម្រូវឲ្យបង្ហាញផងដែរថា សំណើសុំនេះគឺជា "បញ្ហាថ្មីសុទ្ធសាធ"។

30. មេធាវីការពារក្តីពិចារណាឃើញថា បទដ្ឋានទាំងនេះហាក់ដូចជាស្រដៀងគ្នាយ៉ាងខ្លាំង និងសូមលើកឡើងថា បទដ្ឋានទាំងពីរបានឆ្លើយតបទៅនឹងមូលហេតុដូចដែលបានលើកឡើងទាំងអស់។ មេធាវីការពារក្តីបានស្នើសុំឲ្យ លឹម សាត ចូលខ្លួននៅក្នុងឆ្នាំ ២០១១ ដែលសារតែគុណវិបត្តិដែលមានជាក់ស្តែងនៅក្នុងវិធីសាស្ត្រនៃកិច្ចសម្ភាសន៍ស្តាប់ចម្លើយរបស់គាត់ជាមួយ សហចៅក្រមស៊ើបអង្កេត និង និងដើម្បីជជែកតវ៉ាចំពោះសក្ខីកម្មដាក់បន្ទុកដ៏ធ្ងន់ធ្ងរនេះ[57]។ មូលហេតុទាំងពីរនេះបានបង្ហាញយុត្តិកម្មយ៉ាងពេញលេញនៅក្នុងអំឡុងពេលនៃការសួរតទល់។ ទើបតែនៅក្នុងអំឡុងពេលសួរដេញដោលនេះទេ ដែលភាពមិនគួរឲ្យជឿជាក់បានទៅលើភស្តុតាង ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃបានក្លាយជាបញ្ហាច្បាស់ក្រឡែត។ ហេតុដូច្នេះ តម្រូវឲ្យមានការសួរតទល់គ្នាបន្ថែមទៀត។

## **ខ. អង្គជំនុំជម្រះត្រូវតែកោះហៅ [redacted]**

31. ដូចដែលមេធាវីការពារក្តីបានជំទាស់តវ៉ារួចមកហើយ[58] [redacted] បានបដិសេធយ៉ាងច្បាស់ហើយថា នួន ជា មិនបានបញ្ជាឲ្យសម្លាប់អតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរទេ។ យោងតាមកំណត់ត្រានៃកិច្ចសម្ភាសន៍របស់គាត់ជាមួយ Ben Kiernan [redacted] បានរៀបរាប់អំពីការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៧៥ ដែលក្នុងនោះសំណួរផ្សេងៗអំពីគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ត្រូវបាននិយាយថាបានមកយកពិភាក្សាគ្នា។ ពាក់ព័ន្ធនឹងគោលនយោបាយ ដែលទាក់ទងនឹងអតីតមន្ត្រីរបបសាធារណរដ្ឋខ្មែរ កំណត់ត្រារបស់ Ben Kiernan បញ្ជាក់ដូចតទៅ៖

---

[56] *សូមអាន* ឯកសារលេខ **E-9/10.1** "ឧបសម្ព័ន្ធ ឃ៖ សេចក្តីសង្ខេបអំពីសាក្សីជាមួយនឹងចំណុចទាំងឡាយនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១។

[57] ឯកសារលេខ **E-93/4.3** "បញ្ជីបឋម៖ សេចក្តីសង្ខេបអំពីសាក្សី" ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ លេខ ២៥៥។

[58] *សូមអាន* កថាខណ្ឌ ២ *ខាងលើ*។

ពួកគេមិនបាននិយាយថា "សម្លាប់" (ទាហាន លន់ នល់) នោះទេ។ ពួកគេបាននិយាយ (ពាក្យខ្មែរមិនច្បាស់លាស់)។ កុំឱ្យពួកគេស្ថិតនៅក្នុងក្របខ័ណ្ឌការងារ មិនមានន័យថា "កម្ទេច" នោះទេ។ នួន ជា បានប្រើឃ្លានេះ។ កម្ទេច មានន័យថា "សម្លាប់" ប៉ុន្តែ ពួកគេប្រើពាក្យទូទៅមួយថា "កម្ចាត់"[59]។

32. ជាមួយនឹងករណីលើកលែងនៃកំណត់ហេតុចម្លើយ "សាក្សី" ម្នាក់ទៀតដែលមិនចូលខ្លួនមកចំពោះមុខតុលាការនេះ[60] ឃើញថាមិនមានភស្តុតាងដោយផ្ទាល់ទាក់ទងនឹងអត្ថិភាពនៃគោលនយោបាយដើម្បីសម្លាប់អតីតអ្នករដ្ឋការ និងទាហានរបបសាធារណៈរដ្ឋខ្មែរ បញ្ជាក់ថាមាននោះឡើយ។ តាមរយៈការសួរដេញដោលយ៉ាងហ្មត់ចត់ អ្នកជំនាញ Philip Short មិនអាចផ្តល់ឧទាហរណ៍មួយបានឡើយ[61]។ ការដឹងឮដោយផ្ទាល់របស់ [redacted] ចំពោះសម្តីពិតប្រាកដរបស់ នួន ជា ទាក់ទងនឹងបញ្ហាជាក់លាក់នេះ ឃើញថាមិនជាប់ទាក់ទងគ្នានោះឡើយ។ អង្គជំនុំជម្រះត្រូវតែកោះហៅ ហេង សំរិន និងត្រូវតែចាប់បង្ខំគាត់ឱ្យចូលខ្លួន។ ការខកខានមិនបានកោះហៅ នោះវា

---

59 ឯកសារលេខ **E-3/1568** កំណត់ហេតុនៃកិច្ចសម្ភាសន៍ដោយ Ben Kiernan ទំព័រ ២៣។ សូមអានផង ឯកសារលេខ **E-3/1593** "របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាក្រោមរបបខ្មែរក្រហម ពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩" ត្រង់ទំព័រ ៥៧ ([redacted] បានពន្យល់ថា សមាជិករបបមុន "ត្រូវកម្ចាត់ចោល" 'scattered' "កុំឱ្យពួកគេស្ថិតនៅក្នុងក្របខ័ណ្ឌ"–មិនមែន "កម្ទេច" ឬ 'smashed' នោះទេ)។

60 ឯកសារលេខ **E3/387** សេចក្តីថ្លែងរបស់ [redacted] ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ ៦។ អៀង សារី ក៏បានប្រាប់ Stephen Heder ថា គោលនយោបាយបែបនោះមានមែន ប៉ុន្តែ គោលនយោបាយនោះផងដែរ គឺមិនមែនសម្អាងទៅលើការដឹងដោយផ្ទាល់របស់គាត់នោះទេ។ *សូមអាន*ឯកសារលេខ IS-20.6 សេចក្តីថ្លែងរបស់ជនជាប់សង្ស័យ អៀង សារី ហៅ វ៉ាន់ ទំព័រ ៥៦ ដល់ ៦ (ការដឹងឮរបស់ អៀង សារី ដែលគាត់បានអះអាងអំពីគោលនយោបាយបែបនេះត្រូវបានបំពេញបន្ថែមដោយសេចក្តីថ្លែងរបស់គាត់ក្រោយមកទៀតថា គាត់ "មិនបានចូលរួម និងមិនបានដឹងអ្វីទាល់តែសោះអំពីសេចក្តីសម្រេចដែលកំណត់ថា ពួកទាហាន និងអ្នករដ្ឋការស៊ីវិលធំៗ [នៃអតីតរបប លន់ នល់] ត្រូវតែសម្លាប់ចោលនោះទេ)។ ។

61 លោក Short បានថ្លែងនៅត្រង់ចំណុចមួយថា ភី ភួន បានប្រាប់គាត់អំពីគោលនយោបាយបែបនេះ ប៉ុន្តែ ក្រោយមកបានបញ្ជាក់អះអាងថា "លើកលែងតែខ្ញុំនិយាយខុស ខ្ញុំមិនបាននិយាយថា មានគោលនយោបាយដែលបានកំណត់ដោយថ្នាក់លើនោះទេ។ ខ្ញុំអាចយល់ច្រលំ។ អ្វីដែលខ្ញុំបាននិយាយនោះគឺថា វាបានកើតឡើងមែន"។ *សូមអាន*ឯកសារ **E-1/191.1** "ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ៨ ខែ ឧសភា ឆ្នាំ ២០១៣ ទំព័រ ៩៦:១១-៩៧:៥ និង ៩៨:១៥-៩៩:៧។ បន្ថែមលើនេះ ភី ភួន បានបដិសេធចំពោះអត្ថិភាពនៃគោលនយោបាយបែបនេះនៅចំពោះមុខអង្គជំនុំជម្រះ។ *សូមអាន* ឯកសារលេខ **E-1/98.1**"ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ" ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១២ ទំព័រ ៨៨:២-១០។

នឹងធ្វើឱ្យការជំនុំជម្រះនេះមិនមានយុត្តិធម៌ ទាក់ទិននឹងការចោទប្រកាន់នៅទួលពោធិ៍ជ្រៃ។

33. ចៅក្រមនៃអង្គជំនុំជម្រះដែលកំពុងតែជំទាស់ទៅនឹងការចូលខ្លួនរបស់ [redacted] ត្រូវតែពិចារណាលើសេចក្តីសម្រេចនោះឡើងវិញ ដើម្បីបញ្ចៀស "កុំឱ្យមានភាពអយុត្តិធម៌"[62]។ ទោះបីជាមិនអាចយកមកពិភាក្សាបានក៏ដោយ យោងតាមសញ្ញាណថ្មីៗរបស់អង្គជំនុំជម្រះបង្ហាញថា សមាជិកខ្លះរបស់អង្គជំនុំជម្រះ នាពេលនេះ គាំទ្រដល់ការកោះហៅ [redacted] ឱ្យមកផ្តល់សក្ខីកម្មនោះ[63] មេធាវីការពារក្តីកត់សម្គាល់ឃើញថា ការពិចារណាឡើងវិញទៅលើសេចក្តីសម្រេចលើកទីមួយរបស់អង្គជំនុំជម្រះដែលថា សក្ខីកម្មរបស់គាត់មិនមានសារៈសំខាន់ចំពោះសំណុំរឿង ០០២/០១ ក៏នាពេលនេះវាសមស្របហើយ យោងតាមសេចក្តីសម្រេចធ្វើអន្តរាគន៍ដើម្បីដាក់បញ្ចូលការចោទប្រកាន់ពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃ ទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១[64]។សេចក្តីសម្រេចនោះបង្កើតបានជា "ការកែប្រែនៃកាលៈទេសៈ" ដែលធ្វើយុត្តិកម្មដល់ការពិចារណាឡើងវិញនេះ[65]។

## គ. កំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធទៅនឹងទួលពោធិ៍ជ្រៃមិនអាចទទួលយកបានទេ នៅពេលដែលគ្មានការសួរដេញដោល

---

[62] ឯកសារលេខ **C-22/I/68** "សេចក្តីសម្រេចលើពាក្យសុំឱ្យពិចារណាសារជាថ្មី អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង" ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៨ លេខ ERN 00221475-00221475 កថាខណ្ឌ ២៥ (អនុម័តតាមបទដ្ឋានដែលបានធ្វើការពិចារណាឡើងវិញ របស់អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY)។

[63] *សូមអាន* កថាខណ ៦ *ខាងលើ*។

[64] ឯកសារលេខ **E-124/7.3** "ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលបានកែប្រែបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមក្នុងការជំនុំជម្រះ (E138) និងសេចក្តីសម្រេចតបរបស់អង្គជំនុំសាលាដំបូងទៅលើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មមួយចំនួនទៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/០១ (E163) ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១២ ចំណុច 1(vii)។ យោងឯកសារលេខ **E-124/7.2** "ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកខ្លះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ ដែលបានកែប្រែបន្ថែមទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទារបស់ អៀង ធីរិទ្ធ ដើម្បីចូលរួមក្នុងការជំនុំជម្រះ (E138) ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ចំណុច 1(vii)។

[65] *សូមអាន* លេខយោងជើងទំព័រ ៦២ *ខាងលើ*។

34. នៅថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ក្រុមមេធាវីការពារក្តីបានដាក់ការជំទាស់របស់ខ្លួនទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើជាភស្តុតាង[66]។ នៅពេលនោះ ពុំមានសាក្សីណាបានផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងទួលពោធិជ្រៃនោះទេ។ អង្គជំនុំជម្រះនេះបានទទួលស្គាល់ថា មុនពេលទទួលយកកំណត់ហេតុស្តាប់ចម្លើយធ្វើជាភស្តុតាង វាតម្រូវឱ្យមានការពិចារណាថា តើកំណត់ហេតុទាំងអស់នោះមានលក្ខណៈត្រួតគ្នាទៅនឹងសក្ខីកម្មដែលកំពុងផ្តល់ឱ្យដែលត្រូវបានសួរដេញដោលនៅចំពោះមុខអង្គជំនុំជម្រះឬយ៉ាងណា និងត្រឹមវិសាលភាពណា[67]។ ហេតុដូច្នេះ ក្រុមមេធាវីការពារក្តីមិនអាចបង្កើតនូវការជំទាស់ដែលត្រូវបានជូនដំណឹង ពាក់ព័ន្ធទៅនឹងកំណត់ហេតុទាំងឡាយទាក់ទិននឹងទួលពោធិជ្រៃ មុនថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣ នោះបានទេ។ ក្រុមមេធាវីការពារក្តីបានរក្សាសិទ្ធិរបស់ខ្លួនក្នុងការជំទាស់នៅថ្ងៃក្រោយមកទៀតជាជំនួសវិញ និងបានជំទាស់ទៅនឹងការទទួលយកកំណត់ហេតុណាមួយពាក់ព័ន្ធនឹងគោលនយោបាយដែលបានលើកឡើងស្តីពីការកំណត់គោលដៅអតីតទាហាន និង មន្ត្រីសាធារណៈរដ្ឋខ្មែរ[68]។

35. ពេលនេះ ដោយបានស្តាប់ចម្លើយសាក្សីតែចំនួនពីររូបដែលបច្ចុប្បន្ននេះត្រូវបានកំណត់ពេលវេលាឱ្យមកផ្តល់សក្ខីកម្មចំពោះការលើកឡើងទាំងឡាយពាក់ព័ន្ធនឹងទួលពោធិជ្រៃ វាបង្ហាញឱ្យឃើញថា អង្គជំនុំជម្រះមិនអាចទទួលយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីណាម្នាក់ ដែលមិនបានមកចូលរួមការសួរដេញដោលនោះទេ។ ពេលនេះ ពុំមានសក្ខីកម្មដោយផ្ទាល់នៅចំពោះមុខអង្គជំនុំជម្រះដែលបញ្ជាក់ថា មានការសម្លាប់មនុស្សណាមួយបានកើតឡើងនៅទួលពោធិជ្រៃនោះឡើយ[69] និងពុំមានភស្តុតាងដែលអាចឱ្យជឿជាក់បានណាមួយទាល់តែសោះ ស្តីពីចំនួនជនរងគ្រោះដែលត្រូវបានអះអាង[70] ស្តីពីអត្តសញ្ញាណ ឬឋានៈរបស់ជនរងគ្រោះទាំងនោះ[71] ឬស្តីពីទំនាក់ទំនងរវាង

---

[66] *សូមអាន* កថាខណ្ឌ ៥ *ខាងលើ*។

[67] *សូមអាន* កថាខណ្ឌ ៨ *ខាងលើ*។

[68] *សូមអាន* កថាខណ្ឌ ៥ *ខាងលើ*។

[69] *សូមអាន* កថាខណ្ឌ ១១ និង ២២ *ខាងលើ*។

[70] *សូមអាន* កថាខណ្ឌ ១២ *ខាងលើ*។

[71] *សូមអាន* កថាខណ្ឌ ១៣ *ខាងលើ*។

ព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ជាមួយនឹងជនណាម្នាក់ ឬអង្គភាពរដ្ឋបាលណាមួយ ដែលស្និទ្ធទៅនឹងមជ្ឈិមបក្សនោះទេ។

36. ភ័ស្តុតាងដែលត្រូវបានផ្តល់ឲ្យនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីពាក់ព័ន្ធនឹងអង្គហេតុណាមួយក្នុងចំណោមអង្គហេតុដែលត្រូវបានចោទប្រកាន់ទាំងអស់នេះ មិនមានលក្ខណៈត្រូតគ្នាទៅនឹងសក្ខីកម្មដែលកំពុងផ្តល់ឲ្យនោះទេ ហើយនឹងបង្កើតនូវ "ភ័ស្តុតាង" តែមួយគត់នៅចំពោះមុខអង្គជំនុំជម្រះ[72]។ អង្គហេតុទាំងអស់នោះរឹតតែមានសារៈសំខាន់ថែមទៀតទៅដល់រឿងក្តីរបស់ព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីដែលត្រូវបានបង្កើតឡើងដោយ នួន ជា[73]។ អាស្រ័យហេតុនេះ ភ័ស្តុតាងទាំងនោះមិនអាចទទួលយកបានទេនៅពេលដែលគ្មានការសួរដេញដោលនោះទេ។

37. ការសួរដេញដោលពាក់ព័ន្ធទៅនឹងបញ្ហានៃអង្គហេតុជាក់លាក់ទាំងអស់នេះ មានសារៈសំខាន់ជាពិសេស ពីព្រោះសក្ខីកម្មដែលត្រូវបានសួរដេញដោលដោយអង្គជំនុំជម្រះ មិនគ្រាន់តែខកខានមិនបានស៊ើបអង្កេតលើការចោទប្រកាន់ទាំងឡាយនៅក្នុងដីកាដំណោះស្រាយប៉ុណ្ណោះទេ វាថែមទាំងផ្ទុយទៅនឹងការចោទប្រកាន់ទាំងនោះដោយផ្ទាល់តែម្តង។ ទាំង លឹម សាត និង អ៊ុង ឆាត់ ត្រូវបានសួរដេញដោលជាច្រើនសំណួរ និងបានបដិសេធការអះអាងទាំងឡាយ នៅក្នុងដីកាដំណោះស្រាយ ឬបានបង្ហាញថា ពួកគាត់មិនបានដឹងអំពីរឿងទាំងនោះទេ[74]។ សាក្សីទាំង ពីររូបបានទទួលស្គាល់នៅពេលសួរដេញដោលថា អង្គហេតុទាំងឡាយដែលត្រូវបានរៀបរាប់នៅក្នុង កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ខ្លួន មានតម្លៃលើសពីពាក្យចចាមអារ៉ាមដែលគ្មានមូលដ្ឋានច្បាស់លាស់ និងឃ្លាតគ្នាឆ្ងាយបន្តិច។

---

[72] ឯកសារលេខ **E-96** "សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ចុះថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ កថាខណ្ឌ ៩ ដល់ ១០ (កំណត់ហេតុទាំងឡាយមិនអាចទទួលយកបាន ដោយមិនមានការសួរដេញដោលនោះឡើយ ក្នុងករណីដែលកំណត់ហេតុទាំងនោះអាចយកមកធ្វើជាសេចក្តីសម្រេចពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទនោះ)។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា សហព្រះរាជអាជ្ញាសម្រេចតាមបទដ្ឋាននេះ ប៉ុន្តែ នៅបន្តប្រកាន់ជំហរថា ក្នុងកម្រិតអប្បរមា អង្គជំនុំជម្រះត្រូវអនុវត្តវិធានគ្របដណ្តប់ទៅលើការទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមតុលាការមិនអចិន្ត្រៃយ៍នានា។ *សូមអាន* កថាខណ្ឌ ៨ *ខាងលើ*។

[73] *សូមអាន* កថាខណ្ឌ ៨ *ខាងលើ*។

[74] *សូមអាន* កថាខណ្ឌ ១១-១៣ *ខាងលើ*។

38. ស្ថិតក្រោមកាលៈទេសៈទាំងនេះ ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីធ្វើជាភស្តុតាងដោយគ្មានការសួរដេញដោល និងជាការប៉ុនប៉ងក្នុងការបង្ហាញភស្តុតាងដោយគ្មានការពិនិត្យពិច័យ ដែលបានបង្ហាញរួចហើយអំពីអសមត្ថភាពរបស់ខ្លួនក្នុងការជំទាស់ទៅនឹងភស្តុតាងនោះ។ ការទទួលយកភស្តុតាងនេះនឹងបង្កើតបានជាបរាជ័យនៃដំណើរការយុត្តិធម៌ និងជាការរំលោភយ៉ាងខ្លាំងលើសិទ្ធិនានារបស់ជនជាប់ចោទ។

## V. សេចក្តីសន្និដ្ឋាន និងសំណូមពរ

39. ហេតុនេះ ក្រុមមេធាវីការពារក្តីសូមស្នើដោយគោរពសុំឲ្យអង្គជំនុំជម្រះ៖

ក. **កោះអញ្ជើញ** [redacted] និង [redacted] និង [redacted] មកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ និង

ខ. **ដកចេញ** នូវភស្តុតាងពាក់ព័ន្ធនឹងទួលពោធិ៍ជ្រៃដែលមាននៅក្នុងកំណត់ហេតុស្តាប់ ចម្លើយសាក្សី ឬពាក្យបណ្តឹងជនរងគ្រោះ របស់ជនណាម្នាក់ដែលមិនត្រូវបានកោះ ហៅឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។

**សហមេធាវីការពារក្តី នួន ជា**

**សុន អរុណ**

Victor KOPPE